**និយ័តករបរធនបាលកិច្ច**
TRUST REGULATOR
**និយ័តករបរធនបាលកិច្ច**
លេខ:......✓............ ន.ប.ធ.

*ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន

នារសៀលថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១ និយ័តករបរធនបាលកិច្ច (ន.ប.ធ.) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី "**វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច**" តាមរយៈប្រព័ន្ធអនឡាញ Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) និង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច។

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបាននូវធាតុចូល និងមតិយោបល់បន្ថែមពីស្ថាប័នសាធារណៈ វិស័យឯកជន និងបុគ្គលពាក់ព័ន្ធនានា ដើម្បីឱ្យការរៀបចំប្រកាសនេះទទួលបាននូវភាពគ្រប់ជ្រុងជ្រោយ សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធិភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ចនេះ។

ជាមួយគ្នានេះដែរ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះ មានអ្នកចូលរួមសរុបចំនួន ១៥០ រូបដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់ និងជាតំណាងស្ថាប័នរដ្ឋ-ឯកជន ដែលមកពីទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងពាណិជ្ជកម្ម, ក្រសួងយុត្តិធម៌, ធនាគារជាតិនៃកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ស.ហ., និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករមូលបត្រកម្ពុជា, និយ័តករសន្តិសុខសង្គម, និយ័តករគណនេយ្យ និងសវនកម្ម, និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ, អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ., ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, បរធនបាលនៃបរធនបាលកិច្ចដែលបានចុះបញ្ជី, ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ, ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស, ក្រុមហ៊ុនគណនេយ្យករជំនាញ, ក្រុមហ៊ុនមេធាវី, ធនាគារពាណិជ្ជ, ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ។

**និយ័តករបរធនបាលកិច្ច**

អាសយដ្ឋាន : អគារ ១៦៨F (ជាន់ទី៨) សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh